អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងចេញសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៣។

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយរបស់ខ្លួន (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយបានបញ្ជូន មាស មុត ទៅជំនុំជម្រះ ដោយឡែកក្នុងថ្ងៃដដែលនោះដែរ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំងនឹង មាស មុត (ដីកាសម្រេចលើកលែងការចោទប្រកាន់) ។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ ដែលសហព្រះរាជអាជ្ញាជាតិ និងសហមេធាវីជនត្រូវចោទ បានប្តឹងកាលថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ដាច់ដោយឡែកពីគ្នា ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបណ្តឹងឧទ្ធរណ៍ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។

កាលពីថ្ងៃទី២៧, ២៨ និង ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបើកសវនាការលើសំណុំរឿង ០០៣ ដើម្បីស្តាប់អំណះអំណាងរបស់ភាគីនានា។

សាលដីការបស់អង្គបុរេជំនុំជម្រះ នឹងផ្សព្វផ្សាយនៅលើគេហទំព័រ៖ www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**លោក នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh